USAID | CAMBODIA
FROM THE AMERICAN PEOPLE

# DEVELOPMENT INNOVATIONS




# វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះវីដេអូ

## ការនិទានរឿងបែបឆ្នៃប្រឌិត

## សៀវភៅមេរៀន

**Development Innovations** គឺជាគម្រោងរយៈពេលប្រាំឆ្នាំ ក្រោមមូលនិធិជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ **(USAID)** ដើម្បីជួយអង្គការសង្គមស៊ីវិល **(CSOs)** ក្រុមហ៊ុនបច្ចេកវិទ្យា និងសហគ្រាសសង្គមក្នុងការបង្កើត និងប្រើដំណោះ ស្រាយ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT) ដើម្បីដោះស្រាយបញ្ហាប្រឈម ក្នុងការអភិវឌ្ឍន៍នៅ ប្រទេសកម្ពុជា។

សៀវភៅមេរៀននេះស្ថិតក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution 4.0 International License

សៀវភៅនេះត្រូវបានផលិតឡើងក្រោមជំនួយសប្បុរសរបស់ប្រជាពលរដ្ឋអាមេរិកតាមរយៈ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។ ខ្លឹមសារក្នុងសៀវភៅនេះ គឺជាការទទួលខុសត្រូវរបស់ផលិតករ និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ **USAID** រឺ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

# មាតិកា


១. ហេតុអ្វីត្រូវប្រើវីដេអូ ?............................................................ ១
២. ការស្វែងយល់ពីអ្នកមើល............................................................ ១
៣. សារ ............................................................................... ២
៤. វីដេអូ Vox-pop ........................................................................ ៣
៥. បទសម្ភាសន៍ ............................................................................ ៤
៦. ប៊ីរ៉ូល B-Roll ............................................................................ ៧
៧. ការនិទាន .................................................................................៨
៨. ការថតវីដេអូ .........................................................................១០
៩. សេចក្តីណែនាំកម្មវិធីកាត់វីដេអូក្នុងទូរស័ព្ទដៃ.....................................១៤
៩ក. របៀបកាត់តវីដេអូតាម Android ............................................១៦
៩ខ. របៀបកាត់តវីដេអូតាម IOS ......................................................២២

# ១. ហេតុអ្វីត្រូវប្រើវីដេអូ?

វីដេអូគឺជាមធ្យោបាយដ៏ល្អមួយក្នុងចំណោមមធ្យោបាយជាច្រើនដែលប្រើសម្រាប់ផ្សព្វផ្សាយដើម្បីផ្តល់សារ ឬព័ត៌មានលើប្រធានបទជាក់លាក់ណាមួយ នេះដោយសារតែវីដេអូះ

- **មានរូបភាពះ** យើងអាចមើលឃើញរូបភាពលើអេក្រង់។
- **មានចលនាះ** រូបភាពដែលយើងឃើញភាគច្រើនមានចលនាសាច់រឿងរបស់វីដេអូត្រូវបានបង្ហាញតាមរយៈរូបភាពដែលអាចមាន ចលនា។
- **មានពណ៌និងមានសំឡេងះ** វីដេអូមិនត្រឹមតែមានរូបភាពដែលមានចលនាតែប៉ុណ្ណោះទេគឺថែមទាំងមានសំឡេង និងពណ៌ថែមទៀតផង។
- **បញ្ជាក់ពីអារម្មណ៍ះ** រូបភាពដែលមានចលនាអាចជំរុញឲ្យអ្នកមើលមានប្រតិកម្មជាច្រើនដូចជា ព្រួយ រន្ធត់ ឬខឹង។ វាអាចជួយឲ្យអ្នកមើលធ្វើការគិតពិចារណានឹងអាចផ្តល់សារសំខាន់ៗទៅពួកគេ។
- **បង្ហាញពីអ្វីដែលច្បាស់លាស់ះ** តាមរយៈការដាក់កាមេរ៉ាចតត្រង់ចំណុចជាក់លាក់ណាមួយ គឺយើងបានកំណត់គោលដៅច្បាស់លាស់ថាយើងចង់បង្ហាញពីអ្វីដល់អ្នកមើល។
- **បង្ហាញនូវអ្វីដែលមិនអាចមើលដោយភ្នែកទទេះ** មានរឿងជាច្រើនដែលយើងមិនធ្លាប់ដឹងឃើញនឹងស្គាល់ដូចជាកោសិកាតូចៗនៅក្នុងខ្លួនមនុស្សប្រទេសដ៏ឆ្ងាយដែលយើងមិនធ្លាប់ទៅដល់ប៉ុន្តែតាមរយៈវីដេអូយើងអាចឃើញនឹងស្គាល់បានតាមរយៈការមើលលើអេក្រង់ ។
- **ជ្រើសរើសអ្នកមើលះ** វីដេអូនិមួយៗតែងតែកំណត់រួចជាស្រេចថាអ្នកមើលជាអ្នកណា។

# ២. ការស្វែងយល់ពីអ្នកមើល

ការដឹងថាអ្នកមើលវីដេអូរបស់អ្នក ជាអ្នកណា អាចជួយឲ្យអ្នកក្លាយជាអ្នកផលិតវីដេអូដ៏ជោគជ័យម្នាក់។ ដូចនេះអ្នកត្រូវចាំថាអ្នកមើលជាចំណុចសំខាន់នៃការផលិតវីដេអូរបស់អ្នក។

## ក. តើអ្វីខ្លះដែលយើងត្រូវដឹងពីអ្នកមើលរបស់អ្នក?

- ប្រុស ស្រី អាយុ?
- កម្រិតចំណេះដឹង មុខរបរ ឋានៈ?
- ចូលចិត្តអ្វី មិនចូលចិត្តអ្វី ចាប់អារម្មណ៍អ្វី?
- ហេតុអ្វីគេមើលវីដេអូ? តើគេមានតម្រូវការអ្វី? តើវីដេអូរបស់អ្នកអាចឆ្លើយតបតម្រូវការរបស់គេដែរឬទេ?

## ខ. តើធ្វើយ៉ាងណាដើម្បីស្វែងយល់ពីអ្នកមើលរបស់អ្នក?

**និយាយជាមួយពួកគេះ** ទៅជួបពួកគេផ្ទាល់តាមសហគមន៍ សួរសំណួរដែលអ្នកចង់ដឹងនិងបង្ហាញប្រាប់ពួកគេថាពួកគេសំខាន់យ៉ាងណាចំពោះវីដេអូរបស់អ្នក។

**កម្រងសំណួរះ** ធ្វើកម្រងសំណួរដើម្បីសួរទៅកាន់ក្រុមអ្នកមើលដែលជាក់លាក់ដើម្បីដឹងថាអ្នកណាខ្លះចូលចិត្តមើលវីដេអូ តើគេមើលតាមរបៀបណា នឹងហេតុអ្វីគេមើលវីដេអូ។

### គ. បង្កើតកម្រងព័ត៌មានអ្នកមើល

បន្ទាប់ពីប្រមូលព័ត៌មានពីអ្នកមើលបានហើយអ្នកគួរតែបង្កើតកម្រងព័ត៌មានអ្នកមើល នឹងធ្វើចំណាត់ថ្នាក់តាមក្រុមដូចជា ក្រុមក្មេងស្រី ក្រុមក្មេងប្រុស ក្រុមវ័យកណ្ដាល ក្រុមមនុស្សចាស់ នឹងអ្វីជាចំណង់ចំណូលចិត្ត ឬតម្រូវការរបស់ក្រុមនីមួយៗ។

**គួរចងចាំ៖**
ពេលខ្លះយើងអាចបង្កើតវីដេអូយ៉ាងល្អមួយ ប៉ុន្តែវាល្អសម្រាប់តែយើងតែប៉ុណ្ណោះ ហើយបែរជាមិនមែនល្អសម្រាប់អ្នកមើលទៅវិញ នេះជាអ្វីដែលយើងគួរជៀសវាង។ ដូចនេះគ្រប់ពេលវេលាអ្នកត្រូវចាំថាអ្នកមើលគឺជាចំណុចសំខាន់នៃការផលិតវីដេអូរបស់អ្នក។

## ៣. សារ

វីដេអូនិមួយៗ តែងតែមានសារជាក់លាក់មួយផ្ដល់ទៅដល់អ្នកមើល។

**សារដែលល្អនឹង៖**
- ទាក់ទាញចំណាប់អារម្មណ៍អ្នកមើល
- ងាយយល់ នឹងងាយចងចាំ
- លើកទឹកចិត្តឲ្យអ្នកមើលធ្វើអ្វីមួយដែលជាក់លាក់

**សារមួយដែលល្អគួរតែ៖**
- ខ្លីហើយខ្លឹមនិងមិនមានពាក្យជាន់គ្នាច្រើននោះទេ
- បញ្ជាក់ពីបញ្ហាណាមួយជាក់លាក់តាមបែបសាមញ្ញ និងងាយយល់
- បញ្ជាក់ពីហេតុផលជាមួយអ្នកមើលដើម្បីឲ្យពួកគេគិតពិចារណា
- ងាយចងចាំ និងដក់ក្នុងអារម្មណ៍បានយូរ
- មិនទាមទារការពន្យល់បន្ថែម

**ឧទាហរណ៍៖**

"ទឹកគឺជីវិត"
"ពេលស្រវឹង សូមកុំបើកបរ"
"ពាក់មួយសុវត្ថិភាពដើម្បីការពារជីវិតអ្នក"

**គួរចងចាំ៖** ពេលបង្កើតសារថ្មីមួយគួរតែធ្វើការសាកល្បងជាមួយអ្នកដែលមិនបានចូលរួមក្នុងដំណើរការបង្កើតសារដើម្បីចង់ដឹងថាពួកគេយល់យ៉ាងណាចំពោះសារនេះ ហើយយោបល់របស់ពួកគេអាចថ្មី និងមិនមានភាពលំអៀង។

# ៤. វីដេអូ Vox Pop

គឺជាប្រភេទវីដេអូដែលយើងសួរមតិយោបល់ពីមនុស្សនៅតាមទីសាធារណលើប្រធានបទជាក់លាក់ណាមួយ។ វាជាប្រភេទវីដេអូដែលយើងប្រើសំណួរតែមួយសួរទៅមនុស្សច្រើននាក់។

**តើវីដេអូ Vox-Pop មួយដែលល្អគួរមានលក្ខណៈយ៉ាងណា?**

- សំណួរខ្លី សាមញ្ញ និងងាយយល់
- សួរមនុស្សផ្សេងៗគ្នាប្រើសំណួរតែមួយ តែត្រូវច្បាស់ថាពួកគេយល់សំណួរមុនឆ្លើយ
- សួរចំនួនស្មើគ្នារវាងមនុស្សប្រុស និងស្រី
- កុំសួរនៅតែមួយកន្លែងដើម្បីបានទេសភាពផ្សេងៗគ្នា
- សួរមនុស្សគ្រប់ប្រភេទ ក្មេង ចាស់ ប្រុស ស្រី ឬ មនុស្សធ្វើការខុសៗគ្នា ដើម្បីទទួលបានចម្លើយ និងមតិខុសៗគ្នា ហើយទីកន្លែងផ្សេងៗគ្នា
- គួរព្យាយាមរកអ្នកដែលអាចឆ្លើយសំណួរដោយអារម្មណ៍ផ្សេងៗគ្នា ដូចជាខឹង សប្បាយ ឬ ទុក្ខព្រួយ។

**គួរចងចាំ៖** ចំណុចសំខាន់នៃការធ្វើវីដេអូ Vox-Pop គឺជាការឆ្លុះបញ្ចាំងមតិផ្សេងៗគ្នារបស់មនុស្សផ្សេងៗគ្នាលើប្រធានបទតែមួយ។

**ឧទាហរណ៍៖**

| | |
|---|---|
| ឈ្មោះអ្នកផលិត | អាត សុធាវី |
| ទម្រង់វីដេអូ | Video Vox Pop |
| រយៈពេល | ២នាទី សម្រាប់ផ្សាយនៅលើ Facebook |
| ប្រធានបទ | ចរាចរណ៍ |
| គោលបំណង | បង្ហាញពីផលប៉ះពាល់នៃការស្ទះចរាចរណ៍ |
| អ្នកមើល | ប្រជាជនទូទៅ ជាពិសេសអ្នករស់នៅទីក្រុងភ្នំពេញ |
| សារ | រួមគ្នាគោរពច្បាប់ចរាចរដើម្បីជៀសវាងការកកស្ទះចរាចរណ៍ |
| សង្ខេបអំពីវីដេអូ | វីដេអូនេះនិយាយអំពីផលប៉ះពាល់នៃការកកស្ទះចរាចរណ៍ និងលើកទឹកចិត្តឲ្យប្រជាជនទាំងអស់គោរពច្បាប់ចរាចរណ៍ដើម្បីជៀសវៀងការកកស្ទះ។ |
| អ្នកត្រូវសម្ភាសន៍<br>ទីតាំងថត | អ្នកលក់ដូរ សិស្ស អ្នកធ្វើដំណើរ អ្នករត់ម៉ូតូឌុប និង កង់បី<br>ផ្សារកាប់គោ សាលាបាក់ទូក តាមផ្លូវ២៧១ ជិតវត្តសន្សំកុសល |
| សំណួរ | សំណួរ Vox Pop:តើអ្នកយល់ថាការស្ទះចរាចរណ៍បណ្តាលមកពីមូលហេតុអ្វី? |
| B- Roll | សកម្មភាពអ្នកលក់ដូរតាមដងផ្លូវ, សិស្ស និងអ្នកធ្វើដំណើរតាមផ្លូវ អ្នករត់ម៉ូតូឌុប និង កង់បីចាំភ្ញៀវ, ផ្លូវដែលមានចរាចរណ៍កកស្ទះ |

# ៥. បទសម្ភាសន៍

**តើអ្វីជាការធ្វើបទសម្ភាសន៍?**

ការធ្វើបទសម្ភាសន៍ គឺជាការសន្ទនារវាងមនុស្ស ២នាក់ ដោយប្រើសំណួរច្រើនអំពីប្រធានបទជាក់លាក់ណាមួយ ។

## ក.បទសម្ភាសន៍មួយដែលល្អមានលក្ខណៈបែបណា ?

- **មានគោលបំណងច្បាស់លាស់៖** អ្នកត្រូវដឹងថាអ្នកចង់បានអ្វីពីបទសម្ភាសន៍របស់អ្នក ? អាចជាព័ត៌មានពី ប្រធានបទណាមួយ ឬបទពិសោធន៍របស់អ្នកណាម្នាក់។
- **ស្រាវជ្រាវ៖** អ្នកត្រូវធ្វើការស្រាវជ្រាវពីប្រធានបទ ដើម្បីអាចជួយឲ្យអ្នកសួរសំណួរដែលមានភាពឆ្លាតវៃ និងគួរដឹងពីអ្នកដែលត្រូវសម្ភាសន៍ថា គាត់ជាអ្នកណា? ធ្វើអ្វី? នៅទីណា?
- **រៀបចំសំណួរទុកជាមុន៖** គួរត្រៀមសំណួរសម្រាប់សួរទុកជាមុន ឬអាចរៀបចំជាចំណុចគោលៗ សម្រាប់សួរបានដែរ។ យើងមិនត្រូវតែសួរតាមសំណួរដែលបានត្រៀម នោះទុកជាមុនគ្រប់ពេលទេ យើងអាចមានភាពបត់បែន។
- **សំណួរសាមញ្ញ៖** ព្យាយាមធ្វើឲ្យសំណួររបស់អ្នកមានលក្ខណសាមញ្ញ ងាយយល់ សួរត្រង់ៗ និងសួរសំណួរបើក។
- **ការគ្រប់គ្រងបទសម្ភាសន៍៖** ព្យាយាមគ្រប់គ្រងបទសម្ភាសន៍របស់អ្នកកុំឲ្យការពិភាក្សាចេញឆ្ងាយពីប្រធានបទ។
- **ត្រូវមានទំនុកចិត្តក្នុងការសួរសំណួរ៖** ដោយសារអ្នកបានធ្វើការស្រាវជ្រាវនិងបានត្រៀមសំណួររួច ជាស្រេចដូចនេះរឿងអ្វីដែលអ្នកត្រូវបារម្ភនោះទេ ។
- **រក្សាភាពអព្យាក្រឹត៖** ត្រូវចាំថាបទសម្ភាសន៍ដែលអ្នកធ្វើមិនមែនជាគំនិត ឬ មតិរបស់អ្នកនោះទេ ដូចនេះត្រូវគោរពទៅតាមការឆ្លើយរបស់អ្នកដែលយើងសម្ភាស។

## ខ. ការស្រាវជ្រាវជុំវិញបទសម្ភាសន៍

- ការស្រាវជ្រាវជាអ្វីដែលត្រូវធ្វើមុនពេលធ្វើបទសម្ភាសន៍ ព្រោះវាជួយឲ្យអ្នកដឹងពីប្រធានបទដែលអ្នកត្រូវសម្ភាស និងជួយឲ្យអ្នកសួរ សំណួរដែលឆ្លាតវៃ។
- បើសិនជាអាច គួរតែជួបជាមួយអ្នកដែលត្រូវសម្ភាសជាមុន ដើម្បីជាការស្គាល់គ្នានិងយល់ពីគាត់ជាមុន។
- បើត្រូវសម្ភាសអ្នកជំនាញ ឬតំណាងស្ថាប័នណាមួយ គួរតែទៅជួបពួកគាត់ជាមុនដើម្បីស្វែងយល់ថា ពួកគាត់ធ្វើអ្វី? នៅទីណា? ហើយបើអាចយើងគួរយកខិត្តប័ណ្ណ ឬ ព្រឹត្តិបត្រមកអានដើម្បីបានជាព័ត៌មានខ្លះៗ។
- អាចទៅបណ្ណាល័យ អានកាសែត ឬស្ថាប័នណាមួយដែលធ្វើការទាក់ទងនឹងប្រធានបទដែលអ្នកត្រៀមសម្ភាស។
- សាកសួរ មិត្តភ័ក្តិ គ្រួសារ ឬអ្នកណាដែលអ្នកគិតថាដឹងព័ត៌មាន ។

## គ. ស្វែងរកកន្លែងល្អសម្រាប់ធ្វើបទសម្ភាសន៍

កន្លែងមិនសូវល្អធ្វើឲ្យបទសម្ភាសន៍មិនសូវល្អ ដូចនេះត្រូវយកចិត្តទុកដាក់ ក្នុងការស្វែងរកកន្លែងល្អ ពេលធ្វើបទសម្ភាសន៍

- **ត្រូវប្រយ័ត្នកន្លែងមានសំឡេងរំខាន៖** គួរតែរកកន្លែងស្ងាត់ ដែលគ្មានសំឡេងរំខានដូចជា សំឡេងខ្យល់ខ្លាំង សំឡេងម៉ាស៊ីន សំឡេងទូរស័ព្ទ សំឡេងសត្វ ចម្រៀង វិទ្យុ សំឡេងយន្តហោះ ឬសំឡេងអ្វីដែលយល់ថាអាចរំខានដល់បទសម្ភាសន៍របស់អ្នក។
- **ត្រូវប្រយ័ត្នកន្លែងមានអេកូ៖** ប្រសិនបើអ្នកនៅក្នុង បន្ទប់ធំ ឬបន្ទប់ទូលាយហើយបិទជិត គឺអាចមានសំឡេងអេកូ ដូចនេះគួរតែធ្វើការថតសំឡេងសាកល្បងជាមុនសិន។
- **គួរជ្រើសរើសកន្លែងមានផាសុកភាព និងឯកជនភាព៖** សូមរកកន្លែងសមរម្យព្រោះពេលខ្លះ អ្នកដែលយើងត្រូវសម្ភាសមិនចង់ឲ្យអ្នកផ្សេងមើលឃើញគាត់កំពុងនិយាយនោះទេ។
- **គួរព្យាយាមស្វែងរកសំឡេងបរិយាកាសឲ្យត្រូវប្រធានបទ៖** ឧទាហរណ៍៖ សម្ភាសអ្នកនេសាទ យើងអាចឲ្យឮសំឡេងទឹករលក ។

## ឃ. ដើម្បីជួយឲ្យអ្នកដែលយើងត្រូវសម្ភាសត្រៀមខ្លួន យើងគួរប្រាប់គាត់៖

- អ្នកជាអ្នកណា ហើយហេតុអ្វីបានជាអ្នកធ្វើបទសម្ភាសន៍មួយនេះ ?
- ពេលវេលាប្រហាក់ប្រហែលដែល ត្រូវចំណាយក្នុងការសម្ភាសន៍។
- ប្រាប់ថានេះគ្រាន់ជាការថតទុកមិនមែនផ្សាយផ្ទាល់ទេ ដូចនេះគាត់អាចឈប់គ្រាប់ពេល បើគាត់មានអារម្មណ៍ថាគ្មានផាសុកភាព។
- ប្រាប់គាត់ថាយើង នឹងធ្វើការកាត់តបទសម្ភាសន៍នេះ ដូចនេះកុំបារម្ភ បើគាត់និយាយខុសគាត់អាច ឆ្លើយសំណួរម្ដងទៀតបាន។
- គួរតែពន្យល់គាត់ផងថា យើងនឹងសួរសំណួរដែលមានលក្ខណៈបែបណា ។

## ង. ដំណាក់កាលសម្ភាស

ការសម្ភាសន៍ចែកចេញជា៣ ដំណាក់កាលគឺ មុនពេលសម្ភាស ក្នុងពេលសម្ភាស និង បន្ទាប់ពីសម្ភាស។

**មុនពេលសម្ភាសន៍៖**

ចែកតួនាទីគ្នាថាអ្នកណាកាន់កាមេរ៉ា អ្នកណាជាអ្នកសួរ។

**អ្នកកាន់កាមេរ៉ា៖**

- ត្រូវប្រាកដក្នុងចិត្តថា កាមេរ៉ាដំណើរការល្អ មានថ្ម និងកាតមេម៉ូរី ( memory card ) គ្រប់គ្រាន់ពេលធ្វើបទសម្ភាសន៍។
- មុនពេលចាប់ផ្ដើម ត្រូវមើល កម្ពស់អ្នកសួរ និងអ្នកឆ្លើយឲ្យប្រហាក់ប្រហែលគ្នា។
- ថតសាកបន្តិច ហើយបើកមើល ដើម្បីសាកល្បងថាមានសំឡេងគ្រប់គ្រាន់ឬទេ ។

**អ្នកសួរៈ**
- មុនពេលសួរយើងគួរសួរគាត់ថា យើងគួរហៅគាត់យ៉ាងណាក្នុងពេលសម្ភាស ព្រោះអ្នកខ្លះអាចមានតួនាទីលើសពីមួយ។
- គួរទុកពេលឲ្យអ្នកដែលយើងត្រូវសម្ភាស និងអ្នកកាន់កាមេរ៉ាបានត្រៀមខ្លួនរួចរាល់ជាមុនសិន ទើបយើងអាចចាប់ផ្តើមការសម្ភាសបាន។

**ក្នុងពេលសម្ភាសន៍ៈ**
- មានភាពជឿជាក់ ហើយប្រកាន់ខ្ជាប់នូវតួនាទីរបស់យើង។
- ចាប់ផ្តើមដោយការសួរសំណួរបើក ហើយគ្រប់ពេលវេលាលើកទឹកចិត្តឲ្យគាត់ឆ្លើយក្បាលសំណួរមកវិញ។
- បើគាត់មិនយល់សំណួរទេ គួរព្យាយាមពន្យល់គាត់ជាជាងសួរសំណួរដដែលម្តងទៀត។
- កុំនិយាយកាត់ ឬជាន់សំឡេងគ្នា ឬជួយនិយាយបញ្ចប់ឃ្លាជំនួសគេ
- រក្សាភាពរួសរាយរាក់ទាក់ និងញញឹម។
- បើអ្នកយល់ថាការសម្ភាសមានការរអាក់រអួលដោយប្រការណាមួយ អ្នកអាចថតឡើងវិញបាន។

**ក្រោយពេលសម្ភាស**
- **អ្នកសួរៈ** អរគុណ និងសួរថាតើគាត់មានអ្វីបន្ថែមដែរឬទេ។ ប្រមូលព័ត៌មានឲ្យបានគ្រប់គ្រាន់ ដូចជាឈ្មោះជាភាសាខ្មែរ/ឡាតាំងអាយុតួនាទី និងស្ថាប័ន។ បើអាចសួររកនាមប័ណ្ណ ឬឲ្យគាត់សរសេរឈ្មោះឲ្យ។
- **អ្នកកាន់កាមេរ៉ាៈ** បើកមើលវីដេអូដែលបានថតហើយ ដើម្បីច្បាស់ថាការថតគ្មានបញ្ហា។

**ចងចាំ ៖** សូមកុំសន្យាថាវីដេអូនេះនឹងត្រូវបានចាក់ផ្សាយ។

**ឧទាហរណ៍ៈ**

| | |
|---|---|
| ឈ្មោះអ្នកផលិត | អាត សុធារី |
| ទម្រង់វីដេអូ | Video Interview |
| រយៈពេល | ២នាទី សម្រាប់ផ្សាយនៅលើ Facebook |
| ប្រធានបទ | សម្រាមក្នុងទីក្រុង |
| គោលបំណង | បង្ហាញពីផលប៉ះពាល់នៃការបោះចោលសម្រាមតាមសួនសារធារណៈ |
| អ្នកមើល | ប្រចាជនទូទៅ ជាពិសេសអ្នករស់នៅទីក្រុងភ្នំពេញ |
| សារ | ទុកដាក់សម្រាមឲ្យបានត្រឹមត្រូវដើម្បីទីក្រុងស្អាត |
| សង្ខេបអំពីវីដេអូ | វីដេអូនេះនិយាយអំពីផលប៉ះពាល់នៃការបោះសម្រាមតាមសួនសាធារណៈ និង ការលើកទឹកចិត្តឲ្យប្រជាជនទាំងអស់ទុកដាក់សម្រាមឲ្យបានត្រឹមត្រូវ ដើម្បីទីក្រុងស្អាត។ |
| អ្នកត្រូវសម្ភាសន៍ | ពេញ ច័ន្ទសោភា អ្នកដែលតែងតែហាត់ប្រាណលើសួនវិមានឯករាជ្យ |
| ទីតាំងថត | សួនច្បារវិមានឯករាជ្យ |

| | |
|---|---|
| សំណួរ | 1. សូមណែនាំដោយប្រាប់ឈ្មោះ និងមុខរបរ។<br>2. តើអ្នកមកសួននេះញឹកញាប់ដែរឬទេ? ហើយមកធ្វើអ្វីដែរ?<br>3. តើអ្នកយល់ថាការបោះសម្រាមតាមសួនសាធារណៈអាចបង្ករឲ្យមានផលប៉ះពាល់អ្វីខ្លះ?<br>4. តើអ្នកយល់ថាការរក្សាសួនឲ្យស្អាត គ្មានសម្រាមជាតួនាទីអ្នកណា? ហេតុអ្វី?<br>5. តើអ្នកមានយោបល់យ៉ាងណាដើម្បីលើកទឹកចិត្តឲ្យអ្នកដែលមកលេងសួនជួយទុកដាក់សម្រាមឲ្យបានត្រឹមត្រូវ? |
| B-Roll | • សកម្មភាពអ្នកមកលេងសួនមានដើរ មានអង្គុយនិយាយគ្នា លេងកីឡា ឬ ថតរូប<br>• សម្រាមដែលបានបោះចោលលើសួន ដូចជាដបទឹក ស្បោង ឬ សំបកដូង<br>• សម្រាមត្រូវខ្យល់បក់ ប៉ើងស្បោង (បើអាចថតបាន)<br>• ស្រមោច ឬ រុយរោមសម្រាមដែលបានបោះលើសួន<br>• សម្រាមដែលកកស្ទះនៅមាត់លូជិតសួន<br>• ធុងសម្រាមដែលមានដាក់នៅជុំវិញសួន<br>• សកម្មភាពអ្នកមកលេងសួន យកសម្រាមទៅបោះចោលក្នុងធុងសម្រាម<br>• សកម្មភាពអ្នកថែសួន បោសសម្អាតសួន<br>• សកម្មភាពឡានសម្រាម និង បុគ្គលិកអនាម័យលើកសម្រាមចេញពីធុងដែលដាក់តាមសួន |

# ៦.ប៊ីរ៉ូល B-Roll

B-Roll គឺជាវីដេអូបន្ថែម ដែលជួយបង្គ្រប់ន័យ ទៅលើវីដេអូ ចម្បងដែលជា A-Roll ។ បើសិនជាបទសម្ភាសអ្នកជា A-Roll នោះអ្វីផ្សេងទៀតដែលដាក់បន្ថែមនៅក្នុងវីដេអូជា B-Roll ។ ដើម្បីធ្វើ B-Roll បានល្អអ្នកគួរតែ៖

### ក. ធ្វើឲ្យមានភាពពាក់ព័ន្ធគ្នា

B-Roll គួរតែទាក់ទងទៅនឹងអ្វីដែលបានលើកឡើងក្នុងបទសម្ភាសន៍។ បើរូបភាពមិនមានការទាក់ទងនឹងអត្ថន័យសម្ភាស នោះនាំឲ្យមានការរំខាន។

### ខ. រៀបចំទុកជាមុនហើយអាចកែសម្រួលជាបន្តបន្ទាប់

- **B-Roll សម្រាប់ការនិទាន៖** យើងគួរតែគិតដល់ B-Roll ពេលយើងចាប់ផ្តើមធ្វើគម្រោងវីដេអូ ហើយកត់ត្រាទុកថាយើងត្រូវធ្វើB-Rollអ្វីខ្លះ។ ថ្វីត្បិតតែការធ្វើ B-Roll អាចត្រូវត្រៀមទុក ជាមុនតែយើងក៏អាចកែសម្រួលជាបន្តបន្ទាប់ និងធ្វើ B-Roll បន្ថែមទៅតាមស្ថានភាពជាក់ស្តែងបានផងដែរ។

- **B-Roll សម្រាប់បទសម្ភាសន៍៖** ពេលខ្លះយើងត្រូវធ្វើ B-Roll បន្ទាប់ពីយើងសម្ភាសន៍ហើយ ដោយយកទៅតាមអ្វីដែលបានលើកឡើងនៅក្នុងបទសម្ភាសន៍ ។

### គ. ចលនាកាមេរ៉ា និងប្លង់ថត

អ្នកអាចថត B-Roll ដោយធ្វើឲ្យមានចលនាកាមេរ៉ា ឬប្លង់ផ្សេងៗគ្នា ដើម្បីជួយបញ្ជាក់ន័យក្នុងវីដេអូរបស់អ្នក។ អ្នកអាចថត B-Roll ដោយចាប់ផ្តើមពីប្លង់ទូលាយដោយទាញកាមេរ៉ាពីឆ្វេងទៅស្តាំ ឬពីលើចុះក្រោម និងថតការដើរចេញឬចូលខ្លោងទ្វារ ដោយឲ្យអ្នកដែលយើងត្រូវសម្ភាសដើរឲ្យផុតពីប្លង់។

### ឃ. ព្យាយាមកាត់បន្ថយការរំខាន

យើងប្រើ B-Roll ដើម្បីជួយផ្តល់ព័ត៌មានបន្ថែម ដូចនេះ B-Roll នោះមិនសូវច្បាស់ញ៉ាំ គឺនាំឲ្យរំខានដល់វីដេអូរបស់អ្នក។ ដូចនេះគួរជ្រើសរើសរូបភាពណាមិនមានភាពរំខាន។

### ង. ពេលវេលា

យើងអាចធ្វើប្លង់ B-Roll ពី ២០ ទៅ ៣០វិនាទី តែវាក៏អាស្រ័យលើអ្វីដែលចង់បានផងដែរ។ បើរយៈពេលសរុបនៃបទសម្ភាសន៍របស់អ្នកគឺ ២នាទី អ្នកគួរធ្វើ B-Roll ៨ ទៅ ១០ ប្លង់។

## ៧. ការនិទាន

ការនិទាន គឺជានិយាយអធិប្បាយដើម្បីកម្រងឯកសារអធិប្បាយដើម្បីប្រាប់រឿងទៅអ្នកមើល។ ការសរសេរអត្ថបទ ការនិទាន រួមបញ្ចូលការដាក់រូបភាព សំឡេង ហើយធ្វើការរៀបរាប់សាច់រឿងទៅតាមដំណាក់កាល។ អ្នកអាចធ្វើការត្រៀម ដោយដាក់បញ្ចូល ៖

- រូបភាព និង វីដេអូ
- សំឡេង
- បទអធិប្បាយ។

ដើម្បីរៀបចំការនិទាន ដែលទាក់ទាញអារម្មណ៍អ្នកមើល អ្នកគួរតែ៖

- ជ្រើសរើសរូបភាព និងសំឡេងណាដែលគួរឲ្យចាប់អារម្មណ៍
- ប្រយោគនីមួយៗ គួរតែខ្លីហើយងាយយល់
- ជ្រើសរើសពាក្យដោយប្រុងប្រយ័ត្ន គួរមានអត្ថន័យល្អផ្ទួនរណ្តំគ្នា
- ព្យាយាមរក្សាតុល្យភាពរូបភាព និងការអធិប្បាយឲ្យស៊ីគ្នា
- ពេលសរសេរអ្នកអាចចែកជាតារាង ខាងឆ្វេងដាក់ការពណ៌នាអំពីរូបភាពដែលមានក្នុងវីដេអូ ហើយខាងស្តាំដាក់អត្ថបទអធិប្បាយ។

**គួរចងចាំ៖**

- ជ្រើសរើសពាក្យ និងប្រយោគត្រឹមត្រូវក្នុងការនិទានរឿង។
- ការអានបទអធិប្បាយត្រូវតែអានឲ្យស៊ីទៅតាមប្រភេទ វីដេអូ។
- ទាក់ទាញអ្នកមើលដោយ រកអ្នកមានសំឡេងល្អមកអធិប្បាយ។

**ឧទាហរណ៍៖**

| | |
|---|---|
| ឈ្មោះអ្នកផលិត | អាត សុធារី |
| ទម្រង់វីដេអូ | Narration |
| រយៈពេល | ៤នាទី សម្រាប់ផ្សាយនៅលើ Facebook |
| ប្រធានបទ | ព្រះបរមរាជវាំង |
| គោលបំណង | បង្ហាញពីប្រវត្តិរបស់រាជវាំង |
| អ្នកមើល | ប្រជាជនខ្មែរ និង ភ្ញៀវទេសចរណ៍ |
| សារ | ព្រះបរមរាជវាំងត្រូវបានគេកសាងឡើងតាមស្ថាបត្យកម្មប្រពៃណីជាតិដ៏ប្រណិត |
| សង្ខេបអំពីវីដេអូ | វីដេអូនេះនិយាយអំពីប្រវត្តិរបស់ព្រះបរមរាជវាំង |

| លរ | អត្ថបទអធិប្បាយ | រូបភាពដែលមានក្នុងវីដេអូ |
|---|---|---|
| ១ | ព្រះបរមរាជវាំង ជារមណីយដ្ឋានទេសចរណ៍មួយដ៏ពេញនិយមសម្រាប់ភ្ញៀវជាតិ និងអន្តរ-ជាតិ។ | -ទិដ្ឋភាពខាងមុខព្រះបរមរាជវាំង<br>-ក្លោងទ្វាវាំងដែលមានភ្ញៀវជាតិនិងអន្តរជាតិកំពុងដើរចូល |
| ២ | Interview (40 seconds) ជាមួយអ្នកគ្រប់គ្រងការលក់សំបុត្រលើសំនួរ៖<br>1. តើមួយថ្ងៃលក់សំបុត្របានប៉ុន្មានដែរ?<br>2. តើភាគច្រើនជាភ្ញៀវខ្មែរ ឬបរទេស?<br>3. តើការចេញចូលវាំងតម្រូវឲ្យមានការស្លៀកពាក់បែបណាដែរ? | -ទិដ្ឋភាពខាងមុខកន្លែងលក់សំបុត្រ<br>-សកម្មភាពអ្នកលក់សំបុត្រ ភ្ញៀវទិញឲ្យលុយ |
| ៣ | សំណង់ទាំងឡាយក្នុងព្រះបរមរាជវាំងត្រូវបានគេកសាងឡើងទៅតាមស្ថាបត្យកម្មប្រពៃណីជាតិដោយឧកញ៉ាទេពនិម្មិតម៉ក់ជាស្ថាបត្យករដ៏ឆ្នើម។ | -ទាញកាមេរ៉ាពីប្រសាទច័ន្ទឆាយាហើយឈប់ត្រឹមព្រះវិហារព្រះកែវមរកត<br>-ថតឲ្យកៀកលើរូបថតអ្នកឧកញទេពនិម្មិតមក |
| ៤ | Vox-Pop(20 seconds) ជាមួយខ្មែរស្រីម្នាក់(A) និងបរទេសប្រុសម្នាក់(B)ទៅលើសំនួរ៖ ហេតុអ្វីបានជាអ្នកមកទស្សនារាជវាំង? | - រូបភាព (A) ដើរមើលគំនូរតាមប្រាសាទ<br>- រូបភាព (B) ដើរថតរូប និងមើលប្រាសាទ |
| ៥ | ប្រាសាទជាច្រើនមានក្បូរក្បាច់រចនា មានដំបូលច្រើនជាន់ ប្រក់ក្បឿងពណ៌មាស និងមានប្រាង្គកណ្តាលសារពើសូត្រ កំពូលស្រួចបាញ់ទៅលើដែលជានិមិត្តរូបនៃការរីកចម្រើនមិនចេះចប់។ | - ថតចំក្លោងទ្វា ព្រះវិហារកែវមរកត<br>- ថតក្បូរក្បាច់រចនាតាមជញ្ជាំង<br>- ថតដំបូលមានច្រើនជាន់<br>- ថតក្បឿងពណ៌មាស និងទាញកាមេរ៉ាឡើងទៅប្រាង្គកណ្តាលសារពើសូត្រកំពូលស្រួចបាញ់ទៅលើ |

# ៨.ការថតវីដេអូ និងការកាត់វីដេអូ

Video Sequence គឺជាការរៀបបញ្ចូលវីដេអូប្លង់ផ្សេងៗគ្នាអំពីអ្វីមួយដើម្បីឲ្យចេញជាសាច់រឿងមួយ។ ការកាត់តវីដេអូបានល្អ និងបង្កើតឲ្យមានភាពទាក់ទាញនៅក្នុងវីដេអូ។ ដូចនេះហើយយើងត្រូវថតប្លង់ផ្សេងៗគ្នា មុំផ្សេងគ្នា ទីកន្លែងផ្សេងគ្នា រយៈចម្ងាយខុសគ្នា ។ល។ គ្រប់អ្វីទាំងអស់ដែលអ្នកចង់ថត ឬត្រូវថត ត្រូវចាំថាអ្នកគួរថតយ៉ាងហោចណាស់៤ ប្លង់ដូចជាLong shot, Medium shot និង Close up shot ចំនួនពីរផ្សេងគ្នា។ ជាទូទៅអ្នកមិនគួរណាប្រើប្លង់ Long shot ពីរជាប់គ្នានោះទេ។

## ក. ប្លង់ថត

### Rule of Thirds

គឺជាការថតដោយដាក់ចំណុចសំខាន់នៅចំណុចមួយភាគ៣នៃប្លង់ ដែលអាចនៅលើ បញ្ឈរ ឬផ្ដេក។



### Lead Room

គឺជាការថតដោយទុកឲ្យមានចំណុចទូលាយក្នុងប្លង់ទៅតាមភ្នែករបស់មនុស្សដែលនៅក្នុងប្លង់ ឬទៅតាមទិសដៅកម្មវត្ថុដែលកំពុងមានចលនា។



## Extreme Close Up Shot

គឺជាការថតប្លង់ចង្អៀតដោយផ្តោតទៅលើ
ចំណុចតូចៗ ដើម្បីបង្ហាញអំពីភាពលម្អិត
ឬអារម្មណ៍ជាក់លាក់ណាមួយ។



## Close Up Shot

ជាការថតត្រឹមក្បាលពេញមួយប្លង់តែម្តង។



## Medium Close Up Shot

គឺជាការថតពាក់កណ្តាលខ្លួន
ចាប់ពីក្បាលដល់ស្មា។



## Medium Shot

ជាការថតត្រឹមក្បាលចុះដល់ចង្កេះ។



## Long Shot

គឺជាការថតទូលាយឃើញពីក្បាលដល់ចុងជើង ។



## Over the Shoulder Shot

គឺជាការថតពេលមនុស្សពីរនាក់សន្ទនា
ដោយថតពីស្មារមនុស្សម្នាក់
ទៅមុខមនុស្សម្នាក់ទៀត។




Medium close up និង Medium shot ប្លង់ទាំងនេះជាប្លង់ដែលត្រូវប្រើថតបទសម្ភាសន៍។

## ខ. ចលនាកាមេរ៉ា

**Pan** ៖ ជាការថតយកប្លង់ដោយទាញកាមេរ៉ាពីឆ្វេងទៅស្តាំឬ ពីស្តាំទៅឆ្វេង។




**Tilt** ៖ ជាការថតយកប្លង់ដោយទាញកាមេរ៉ាពីលើចុះក្រោម ឬពីក្រោមឡើងទៅលើ។



# ៩. សេចក្តីណែនាំកម្មវិធីកាត់វីដេអូក្នុងទូរស័ព្ទដៃ

កម្មវិធីកាត់តវីដេអូតាមទូរស័ព្ទមានច្រើនប្រភេទដែលអាចផ្តល់នូវមុខងារផ្សេងៗគ្នាក្នុងការកាត់តវីដេអូ។ នៅក្នុងសៀវភៅមេរៀននេះនឹងលើកយកកម្មវិធីកាត់តវីដេអូចំនួនពីរយកមកបង្ហាញ។

| APP / FUNCTION | iMovie-Movie Maker (Android) | iMovie (IOS) |
|---|---|---|
| A-Roll | ✔ | ✔ |
| B-Roll | ✔ | ✔ |
| Sound | ✔ | ✔ |
| Watermark | ✔ | ✘ |
| Text | ✔ | ✔ |
| Pro Version | ✔ | ✘ |
| Limited duration | ✘ | ✘ |
| Capacity Required | Anroid 4.1 or later | iOS 9.3 or later |

# សេចក្តីណែនាំកម្មវិធីកាត់តវីដេអូក្នុងទូរស័ព្ទដៃ




កម្មវីធី iMovie - Movie Maker គឺជាកម្មវិធីកាត់តវីដេអូ សម្រាប់ប្រភេទទូរស័ព្ទ Android ។

ដើម្បីទាញយកកម្មវិធីនេះ អ្នកអាចចូលទៅទាញយក ដោយចូលទៅ Google ហើយវាយ Free editing movie create video easily - APK វាមានរូបរាងដូចបង្ហាញនៅខាងឆ្វេង។

ចុចលើពាក្យ Install ដើម្បីទាញកម្មវិធីចូលទូរស័ព្ទរបស់អ្នក។




កម្មវីធី iMovie គឺជាកម្មវិធីកាត់តវីដេអូសម្រាប់ប្រភេទទូរស័ព្ទ iOS ។

ដើម្បីទាញយកកម្មវីធីនេះ អ្នកអាចចូលទៅរកវានៅ App Store ហើយវាយថា iMovie។ វាមានរូបរាងដូចដែលបានបង្ហាញក្នុងរូបខាងឆ្វេង។

ចុចលើពាក្យ GET ដើម្បីទាញកម្មវិធីចូលទូរស័ព្ទរបស់អ្នក។

## ៩ក. របៀបកាត់តវីដេអូតាម Android

- ដើម្បីដំណើរការកម្មវិធី អ្នកត្រូវ បើក **iMovie Editing** ជាមុនសិន បន្ទាប់មកផ្ទាំងកម្មវិធីនឹងចេញជារូបរាងដូចខាងក្រោម៖

- ចូរចុចទៅលើ + ដើម្បីបង្កើតគម្រោង Project ថ្មី




១

- ដើម្បីប្តូរឈ្មោះគម្រោង ( Project ), សរសេរនៅកន្លែង New Movie

- ចូរចុចទៅ Create ដើម្បីបង្កើត Project




២

- បន្ទាប់មកចុចទៅលើ Done ដើម្បីចូលក្នុង Project ដែលយើងបានបង្កើត




៣

ក្រោយពីចុច Done រួច ផ្ទាំងទាំងមូលរបស់ iMovie Editing នឹងចេញជារូបរាងដូចខាងក្រោម៖




៤

- ដើម្បីជ្រើសរើសវីដេអូមកកាត់ សូមចុច ➕

- បន្ទាប់មកចុចលើ Video




៥

-បន្ទាប់មក អ្នកនឹងឃើញផ្ទាំងនេះចេញជារូបរាងដូចខាងក្រោម៖

-សូមជ្រើសរើស វីដេអូ ដែលអ្នកចង់យកមកកាត់




៦

**ការកាត់** A-Roll

- មុននឹងធ្វើការកាត់វីដេអូ សូមចុចទៅលើ Clip នៅខាងក្រោម ( clipនៅកន្លែងកាត់វីដេអូ )ពីរដងឲ្យញាប់ ( Double Click) នោះវានឹងចេញ Tool មួយចំនួនដូចរូបខាងក្រោម៖







៧

**ចំណាំ៖**

- ដើម្បីសាកមើលវីដេអូ ចុចទៅលើកន្លែងណាមួយដែលជាកន្លែងបង្ហាញវីដេអូ ( A ) ឲ្យញាប់ពីរដង។

- ដើម្បីចាកចេញទៅកន្លែងដើមអាច ចុចលើ Done ឬសញ្ញា




៩

- ដើម្បីកាត់ផ្តាច់វីដេអូ ចូរអ្នកយកខ្សែបន្ទាត់ដាក់ត្រង់ចំណុចដែលអ្នកចង់កាត់ ហើយចុចលើរូបកន្ត្រៃ។ ក្រោយពីអ្នកកាត់ផ្តាច់រួចហើយ អ្នកអាចលុបវីដេអូនោះបានដោយចុចទៅលើ clip ឲ្យញាប់២ដង ( Double Clicks)ហើយចុចលើ



១០

**ការកាត់** B-Roll

- ដើម្បីទាញយក វីដេអូ ដោយចុចទៅលើ ហើយអ្នកអាចធ្វើការប្តូរកន្លែងវាបាន ដោយគ្រាន់តែយកដៃសង្កត់ទៅវីដេអូ ហើយអូសវាទៅលើទៅក្រោម ឬផ្លាស់ប្តូរលំដាប់របស់វា




១១

**របៀបបន្ថែមសម្លេង**

- អ្នកធ្វើការថតសំលេងដោយគ្រាន់តែចុចលើ ហើយយក Sound សំលេងរបស់អ្នកនឹងចាប់ផ្តើមធ្វើការ record ដោយខ្លួនឯង

- ចុចទៅលើ នៅពេលដែលអ្នកឈប់ record



១២

- អ្នកអាចដាក់ភ្លេងបានដោយគ្រាន់តែចុចទៅលើសញ្ញា ហើយយកពាក្យថា Sound ។ ផ្ទាំងកម្មវិធីនឹងចេញជារូបរាងដូចខាងក្រោម៖
- អ្នកអាចធ្វើការសាកស្តាប់ភ្លេងដោយចុចទៅលើ






ចំណាំ៖

- អ្នកអាចធ្វើការតំឡើង ឬបន្ថយសម្លេងដោយគ្រាន់តែចុចលើសម្លេងនោះឲ្យញាប់២ដង ហើយចុចទៅលើ
- អ្នកអាចតំឡើង ឬបន្ថយសម្លេងបាន






## របៀបដាក់អក្សរ

ដើម្បីដាក់អក្សរអ្នកត្រូវ៖

- ចុចទៅលើសញ្ញា ហើយយកពាក្យថា Text

ក្រោយពីចុចហើយអ្នកនឹងឃើញផ្ទាំង keyboard សម្រាប់អ្នកដើម្បីសរសេរអ្វីដែលអ្នកចង់សរសេរ






- ក្រោយពីបានដាក់អក្សរហើយ សូមចុចទៅលើសញ្ញា ដើម្បីយល់ព្រម



នៅពេលអ្នកចុចលើអក្សរវានឹងមានចេញរូបដូចខាងក្រោម៖




១៧




១៨

**ការដាក់ Transitions**

- ចុចទៅលើសញ្ញា ហើយ

- ជ្រើសរើស transition មួយដែលអ្នកពេញចិត្តដែលបាន បង្ហាញដូចរូបខាងក្រោម៖




១៩

**ការបញ្ចេញ វីដេអូ** ( Export )

- ដើម្បីបញ្ចេញវីដេអូសម្រេចសូមចុចទៅលើ

- បន្ទាប់មកអ្នកនឹងឃើញផ្ទាំងដូចក្នុងរូប៖




២០

- ជ្រើសរើស( គុណភាពល្អ គុណភាពមធ្យម និងគុណ-ភាពទាប )ទៅតាមគុណភាពដែលអ្នកចង់បាន




២១

- ក្រោយពីបានបញ្ចប់អ្នកអាចរកវីដេអូសម្រេចរបស់អ្នកក្នុង Camera Album

- សូមរង់ចាំដល់ការបញ្ចេញវីដេអូរបស់អ្នកត្រូវបានបញ្ចប់







២២

## ៩ខ. របៀបកាត់តវីដេអូតាម IOS

- ដើម្បីដំណើរការកម្មវិធី អ្នកត្រូវ បើក **iMovie** ជាមុនសិនបន្ទាប់មកផ្ទាំងកម្មវិធីនឹងចេញជារូបរាងដូចខាងក្រោម៖

- ចូរចុចទៅលើ Continue ដើម្បីបន្តកម្មវិធី




១

- ចូរចុចទៅលើ ＋

- បន្ទាប់មកចុចទៅ Movie ដើម្បីបង្កើត Project




២

អ្នកនឹងឃើញផ្ទាំងទាំងមូលរបស់ iMovie នឹងចេញជារូបរាងដូចខាងក្រោម៖

- ចូរចុចលើវីដេអូណាមួយដែលអ្នកពេញចិត្តដើម្បីយកមកកាត់




- ចូរចុចលើសញ្ញា ✓ លើវីដេអូ បន្ទាប់មកចុចលើពាក្យ "Create Movie"

៣

ក្រោយពីចុច Create Movie រួច ផ្ទាំងទាំងមូលរបស់ iMovie Editing នឹងចេញជារូបរាងដូចខាងក្រោម៖




៤

**ការកាត់វីដេអូ** A-Roll

-មុននឹងធ្វើការកាត់វីដេអូ សូមចុចទៅលើ Clip នៅខាងក្រោម ( clipនៅកន្លែងកាត់វីដេអូ )ពីរដងឲ្យញាប់ ( Double Clicks) នោះវានឹងចេញ Tool មួយចំនួនដូចរូបខាងក្រោម៖




៥

- ដើម្បីកាត់វីដេអូ ដាក់ខ្សែបន្ទាត់លើចំណុចដែលចង់កាត់ ហើយចុចលើសញ្ញា ✂ ហើយចុចលើពាក្យថា Split

- ចុចលើ clip ណាមួយដែលអ្នកចង់កាត់ចោល ដោយចុចពាក្យ Delete




៦

**ចំណាំ៖**

វីដេអូទាំងអស់នៅក្នុង Project អាចផ្លាស់ប្តូរទីតាំងដោយយកដៃសង្កត់លើវាឲ្យជាប់ ហើយអូសទៅទីតាំងណាដែលអ្នកពេញចិត្ត

៧

**ការកាត់វីដេអូ** B-Roll

- ដាក់ខ្សែរបន្ទាត់លើចំណុចដែលអ្នកចង់បន្ថែម B-Roll

- បន្ទាប់មកចុចលើសញ្ញា + ហើយជ្រើសរើសវីដេអូដែលអ្នកពេញចិត្ត




៨

ចំណាំ៖
មុនពេលដែលអ្នកទាញវីដេអូដើម្បីយកមកកាត់អ្នកអាចចុចទៅលើសញ្ញា ••• ដើម្បី

- បន្ថែម "តែសំលេង" របស់វីដេអូ ចុចលើប៊ូតុង
- បន្ថែម វីដេអូ B-Roll ចុចលើប៊ូតុង




៩

- បន្ថែម វីដេអូនៅ screen ខាងលើឆ្វេង ចុចលើប៊ូតុង

- បន្ថែម វីដេអូនៅ screen មួយចំហៀង ចុចលើប៊ូតុង




១០

- B-Roll អាចទាញលើកប្តូរទីតាំងបានដោយគ្រាន់តែយកដៃអ្នកសង្កត់លើវីដេអូនោះហើយប្តូរកន្លែង

- អ្នកអាចទាញពង្រីក ឬបង្រួមបានដោយគ្រាន់តែយកដៃអ្នកសង្កត់លើវីដេអូនោះហើយទាញវាពង្រីក ឬបង្រួម







១១

## របៀបបន្ថែមសម្លេង

- ចូរអ្នកចុចលើសញ្ញា + ដើម្បីទាញយកសំលេងបន្ថែម ហើយចុចលើពាក្យថា Audio

- បន្ទាប់មកផ្ទាំងកម្មវិធីនឹងចេញជារូបរាងខាងក្រោម៖







- ជ្រើសរើសសម្លេងណាដែលអ្នកពេញចិត្ត ដោយចុចទៅលើពាក្យuse

១២

- អ្នកអាចធ្វើការកាត់ ឬតម្លើងសម្លេងដោយគ្រាន់តែចុច ទៅលើសម្លេងនោះពីរដងឲ្យញាប់( Double Clicks) អ្នកនឹងឃើញដូចផ្ទាំងខាងក្រោម៖




១៣

- អ្នកអាចធ្វើការកាត់សម្លេងដោយចុចលើ ✂ ហើយ ចុចលើពាក្យ Foreground ប្រសិនបើអ្នកចង់លឺសម្លេងលើវីដេអូរបស់អ្នក( សម្លេងក្នុងវីដេអូនឹងត្រូវបានបិទ )

អ្នកអាចប្តូរវាទៅជា Background ប្រសិនបើចង់ឲ្យលឺសម្លេងទាំងពីរ

១៤

- អ្នកអាចធ្វើការតំឡើង ឬបន្ថយសម្លេងដោយគ្រាន់តែចុចលើសម្លេងនោះពីរដងឲ្យញាប់( Double Click)ហើយចុចទៅលើ🔊អ្នកអាចទាញវាទៅស្តាំដើម្បីតម្លើងសម្លេង ឬឆ្វេងដើម្បីបន្ថយសម្លេង




១៥

- ដើម្បីថតសម្លេងអ្នកត្រូវចុចលើសញ្ញា + ហើយយកពាក្យថា Voiceover ។ ផ្ទាំងកម្មវិធីនឹងចេញជារូបរាងដូចខាងក្រោម៖

- អ្នកអាចថតសម្លេងបានដោយគ្រាន់តែទាញខ្សែរបន្ទាត់ទៅកន្លែងដែលអ្នកចង់ Record




១៦

- បន្ទាប់មកចុចទៅលើ Record ដើម្បីចាប់ផ្ដើមធ្វើការថតសម្លេង។ វានឹងលោតចេញ 3 2 1 សម្រាប់ឲ្យអ្នកត្រៀមខ្លួនមុនពេលrecord
- ចុចទៅលើពាក្យ Stop បើអ្នកចង់ឈប់

១៧

- បន្ទាប់មកកម្មវិធីនឹងសួរអ្នក ថាតើយល់ព្រមយកសម្លេងដែលបាន record ហើយឬនៅ
- ដើម្បីធ្វើការថតម្ដងទៀត ចុចទៅលើពាក្យថា Retake




១៨

- ដើម្បីចង់សាកស្ដាប់ ចុចទៅលើ Review ។ បើពេញចិត្ត ចុចលើពាក្យAccept
- ប្រសិនបើយល់ព្រមសូមចុចទៅលើពាក្យថា Accept

១៩

**របៀបដាក់អក្សរ**

- ចុចទៅលើ clip ឲ្យញាប់ពីរដង( Double Click) ហើយ ចុចលើសញ្ញា T សម្រាប់ដាក់អក្សរ។ អ្នកនឹងឃើញមាន style ជាច្រើនឲ្យអ្នកជ្រើសរើស




២០

- ចុចទៅលើអក្សរដែលបានលោតចេញនោះដើម្បីធ្វើការផ្លាស់ប្តូរText របស់អ្នកហើយអ្នកនឹងឃើញផ្ទាំង keyboard សម្រាប់អ្នកសរសេរអ្វីដែលអ្នកចង់សរសេរ

- អ្នកអាចប្តូរទីតាំងអក្សរដោយយកដៃដាក់លើវាហើយរំកិលតាមចិត្ត

- ចុចទៅលើ None បើចង់ដក title នោះចេញវិញ

២១

## ការដាក់ Transitions

នៅចន្លោះពី clip មួយទៅ clip មានសញ្ញាវីដេអូ Transition

- គ្រាន់តែចុចលើវា ហើយជ្រើសរើស transition មួយដែលអ្នកពេញចិត្តដែលបានបង្ហាញដូចរូបខាងក្រោម៖




- បើអ្នកមិនចង់ដាក់អាចចុចលើ None

២២

## ការបញ្ចេញ វីដេអូ ( Export )

- ដើម្បីបញ្ចេញវីដេអូសម្រេចសូមចុចទៅលើ Done ហើយចុចទៅលើសញ្ញា

- ចុចលើពាក្យថា Save Video

- ប្រសិនជាអ្នកចង់ post វីដេអូក្នុង Facebook ចុចទៅលើ Facebook




២៣

- សូមរង់ចាំដល់ការបញ្ចេញវីដេអូរបស់អ្នកត្រូវបានបញ្ចប់

- ក្រោយពីបានបញ្ចប់អ្នកអាចរកវីដេអូសម្រេចរបស់អ្នកក្នុង Photo Library




២៤